[redacted]

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ១២៧
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១

សាលដីកា
លេខ ៤៧៤ "ជ"
ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ដោយមានសមាសភាពដូចខាងក្រោម ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ ១២៧ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២១ មានដូចខាងក្រោម ៖

-ជនជាប់ចោទ ឈ្មោះ [redacted] ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ មានទីកន្លែងកំណើត នៅភូមិរតនៈ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង និងមានទីលំនៅបច្ចុប្បន្នផ្ទះលេខ១២៤ ក្រុមទី០៤ ភូមិរតនៈ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៤នាក់ ទោសពីមុន "គ្មាន" ។ (ក្រៅឃុំ)

ដោយមានលោក [redacted] រគ្គលេខ ១៨០១ និងលោកស្រី [redacted] រគ្គលេខ ១៤០៤ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។



[redacted]

ជាប់ចោទពីបទ៖ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ភេទប្រុស អាយុ៦៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ។

ដោយមានលោក [redacted] អត្តលេខ ៥០៤ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

## អំពីអង្គហេតុ

កាលពីឆ្នាំ១៩៩៧ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានទិញដីមួយកន្លែងទំហំ៥.០០០ ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ដោយមិនបានធ្វើលិខិតទិញលក់ទេ គ្រាន់តែបានប្រគល់បង្កាន់ដៃបង់ប្រាក់ និងបង្កាន់ដៃទទួលពាក្យប៉ុណ្ណោះពីឈ្មោះ [redacted] ។ លុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ឈ្មោះ [redacted] បានធ្វើលិខិតផ្ទេរសិទ្ធិដីនោះដោយបន្លំស្នាមមេដៃអ្នកលក់ឈ្មោះ [redacted] ហើយបានយកលិខិតនោះទៅចុះហត្ថលេខាពីអាជ្ញាធរមានសមត្ថកិច្ច ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេច ៖

១/.ផ្តន្ទាទោសឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ ដោយអនុវត្តទោសព្យួរ

ពីបទ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ គាត ស៊ីថា និងចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ១២៧ ព្រទ.ឧបប/២១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង។

-បានឃើញ របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង



[redacted]

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនសុំបដិសេធការចោទប្រកាន់ខាងលើ ព្រោះខ្លួនមិនបានធ្វើការក្លែងបន្លំអ្វីទេ ។ ខ្លួនទិញដីនៅឆ្នាំ១៩៩៧ ទិញដីពីឈ្មោះ [redacted] ទិញហើយខ្លួនទុកឱ្យពួកគាត់ធ្វើស្រែរហូតដល់ម្តាយខ្លួនស្លាប់នៅឆ្នាំ២០០៦ អញ្ចឹងនៅឆ្នាំ២០០៧ នឹងឪពុករបស់ខ្លួនចង់បានប្រពន្ធទៀតក៏ឱ្យខ្លួនលក់ដីនឹងទៅគាត់ទុកការប្រពន្ធ ។ ដល់តែពេលឆ្នាំ២០០៨ គាត់ត្រូវការប្រពន្ធគាត់អត់មានលុយ ខ្លួនក៏ធ្វើលិខិតផ្ទេរសិទ្ធិដីពី [redacted] មកខ្លួនឈ្មោះ [redacted] នឹង ផ្ទេរសិទ្ធិតាំងពីនឹងរហូតមកដល់ទាញខ្លួនឱ្យទៅយកលុយធនាគាររហូតដល់ឆ្នាំ២០១៨ គាត់មកសុំវិញខ្លួនមិនឱ្យ ដល់តែពេលឆ្នាំ២០១៩ នេះគាត់លួចទៅបង់លុយឱ្យធនាគារហើយដកប្លង់នឹងមកលក់ដីនឹងបាត់ ។ ដីទំនាស់ខាងលើជាដីរបស់ខ្លួនពិតប្រាកដមែន ដែលខ្លួនបានទិញពីឈ្មោះ [redacted] ដោយឈ្មោះ [redacted] បានប្រគល់បង្កាន់ដៃបង់ប្រាក់ និងកាន់កាប់ដីឱ្យខ្លួនចំនួន ០៤សន្លឹក ។ ក្នុងការទិញលក់នោះឈ្មោះ [redacted] និងឈ្មោះ [redacted] គឺអ្នកផ្តិតមេដៃជាសាក្សីចំពោះមុខមេភូមិ ។ ចំពោះស្នាមមេដៃរបស់ឈ្មោះ [redacted] គឺមេភូមិជាអ្នកឱ្យឈ្មោះ [redacted] ផ្តិតឱ្យ ។ ខ្លួនមិនមែនជាអ្នករៀបចំធ្វើលិខិតទិញលក់ ឬឯកសារផ្ទេរសិទ្ធិអ្វីទេ គឺមេភូមិ និងអនុភូមិជាអ្នកសរសេរបំពេញឱ្យ ។ បច្ចុប្បន្នអ្នកលក់ដីឈ្មោះ [redacted] បានស្លាប់បាត់ទៅហើយ ។ ការផ្តិតមេដៃលើលិខិតនោះគឺធ្វើនៅមេភូមិដោយមានខ្លួនជាអ្នកទិញ និងមានសាក្សីចំនួន ០២នាក់ គឺឈ្មោះ [redacted] និងឈ្មោះ [redacted]។ នៅពេលនោះឈ្មោះ [redacted] មិនបានជួបគ្នាពេលទិញលក់ទេ ។ កន្លងមកឪពុកចុងខ្លួនឈ្មោះ [redacted] បានប្រាប់ខ្លួនថា ឱ្យលក់ដីនោះទៅហើយគាត់សុំ១.០០០ដុល្លារអាមេរិក ដើម្បីការប្រពន្ធថ្មី ។ ពេលនោះខ្លួនក៏បានយកបង្កាន់ដៃដីឈ្មោះ [redacted] ទៅធ្វើប្លង់ទន់ដើម្បីយកខ្ចីប្រាក់ធនាគារតែម្តង ។ ចំពោះលិខិតមួយដែលបានអះអាងថាខ្លួននឹងប្រគល់ដីខាងលើឱ្យទៅឪពុកវិញ នៅពេលដែលខ្លួនបង់លក់ពីធនាគាររួចអស់ ។ សំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយរកយុត្តិធម៌ជូនដល់ខ្លួនផង ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ការជំនុំជម្រះពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីបទ ក្លែងបន្លំឯកសារសាធារណៈ ហើយចំពោះការផ្តន្ទាទោស០៥ឆ្នាំជនជាប់ចោទមិនសុខចិត្តនឹងការសម្រេចនេះជនជាប់ចោទក៏បានប្តឹងឧទ្ធរណ៍ ។ ដោយសារការសួរវែកញែកទាក់ទងទៅនឹងរឿងដីធ្លីមួយកន្លែងដែល [redacted] គាត់បញ្ជាក់អង្គហេតុថា ជាកម្មសិទ្ធិគាត់ដែលបានទិញផ្ទាល់ពីម្ចាស់ដើមឈ្មោះ [redacted] នេះតាមការអះអាងរបស់ [redacted] ដាក់នៅក្នុងសំណុំរឿង ហើយការទិញនេះគឺគាត់ពីរនាក់ប្តីប្រពន្ធហើយប្រពន្ធរបស់គាត់ក៏បានស្លាប់ទៅ ។ ការគ្រប់គ្រងកាន់កាប់ឯកសារដីនេះគឺឱ្យទៅ [redacted] ជាអ្នកគ្រប់គ្រង ហើយអង្គហេតុបន្ទាប់ខ្វះខាតលុយត្រូវបានដើមបណ្តឹងឱ្យ [redacted] ទៅខ្ចីប្រាក់ធនាគារតែការខ្ចីប្រាក់ធនាគារ [redacted] បញ្ជាក់ថាដីនេះអត់មានឈ្មោះរបស់គាត់អញ្ចឹងគឺខ្ចីមិនបានទេ ការដែលដើមបណ្តឹងគាត់មិនចេះអក្សរអញ្ចឹងមានឯកសារខ្លះយកទៅឱ្យដើមបណ្តឹងគាត់ផ្តិតមេដៃ ហើយរហូតដល់ពេលគាត់ដាក់ប័ណ្ណធនាគារក្រោយមកបានគាត់ដឹងថាការចេញប្លង់ធនាគារគឺឈ្មោះ [redacted] ជាម្ចាស់កម្មសិទ្ធិដីធ្លីក្នុងពេលនោះហើយដែលមានការបញ្ជាក់ក្នុងការចង់បានដីនោះលក់ ចង់បានដីនោះមកធ្វើជាកម្មសិទ្ធិ និងអង្គហេតុផ្សេងទៀតនៅក្នុងរឿងរដ្ឋប្បវេណី ក្នុងការបញ្ជាក់ការទាមទារនូវកម្មសិទ្ធិនោះ ។ ការបញ្ជាក់នេះគឺក្រោយមកបញ្ជាក់ថាសាក្សីមួយចំនួននៅក្នុងអង្គហេតុរឿងព្រហ្មទណ្ឌនេះថាការធ្វើឯកសារនៅក្នុងការផ្ទេរកម្មសិទ្ធិពីឈ្មោះ [redacted] មក [redacted] សាក្សីមួយចំនួនទាំងអស់គឺបានបដិសេធថាគាត់មិនបានផ្តិតមេដៃអត់បានធ្វើឯកសារអ្វីនោះទេក្នុងការប្រគល់សិទ្ធិកម្មសិទ្ធិទៅឱ្យ [redacted] នេះ ។ ដូច្នេះរាល់ការបដិសេធនេះ[illegible] ឯកសារដែលមានឈ្មោះ [redacted] ជាម្ចាស់កម្មសិទ្ធិដែលគាត់ធ្វើមិនត្រឹមត្រូវទៅតាមនីតិវិធី ឬក៏ក្លែងបន្លំស្នាម



[redacted]

មេដៃជាដើមដែលតុលាការថ្នាក់ក្រោមបានបញ្ជាក់ថាឯកសារធ្វើឡើងមិនត្រឹមត្រូវ ។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឈ្មោះ [redacted] គាត់បានទិញដីពីឈ្មោះ [redacted] មិនបានធ្វើលិខិតស្នាមទេ គ្រាន់តែប្រគល់បង្កាន់ដៃទទួលប្រាក់ និងបង្កាន់ដៃទទួលពាក្យចំនួន០៤សន្លឹក តូចៗ ពីឈ្មោះ [redacted] ។ នៅឆ្នាំ២០០៦ ប្រពន្ធរបស់គាត់បានស្លាប់ដែលត្រូវជាម្តាយរបស់ឈ្មោះ [redacted] ស្លាប់អញ្ចឹងគាត់បានឱ្យកូនស្រីគាត់ម្នាក់យកបង្កាន់ដៃ០៤សន្លឹកនឹងមក [redacted] រក្សាទុក ។ នៅឆ្នាំ២០០៨ គាត់មានគម្រោងរៀបអាពាហ៍ពិពាហ៍ប្រពន្ធមួយទៀតគាត់ថាឱ្យប្រគល់បង្កាន់ដៃនឹងមកដើម្បីគាត់យកទៅបញ្ចាំគេយកលុយមកឱ្យការប្រពន្ធ ។ ឈ្មោះ [redacted] គាត់ថាមិនបាច់ទេផ្តិតមេដៃឱ្យគាត់មកខ្លួននឹងបំពេញបែបបទខ្ចីប្រាក់ពីគេឱ្យពុកឯង អញ្ចឹង [redacted] នឹងគាត់បានផ្តិតមេដៃមែននៅលើលិខិតនឹងមែនប៉ុន្តែមិនដឹងថាជាលិខិតអ្វីទេ គាត់អះអាងថាជាលិខិតខ្ចីប្រាក់គេ ក្រោយពីផ្តិតមេដៃរួច [redacted] នឹងបានយកប្រាក់មកឱ្យ [redacted] មែន ប៉ុន្តែមិនដឹងថាខ្ចីពីអ្នកណា គឺមិនដឹងទេ ក្រោយមកគាត់ក៏បានសងប្រាក់ទៅ [redacted] គ្រប់ចំនួនវិញ គាត់ក៏បានទាមទារបង្កាន់ដៃនោះមកវិញ ប៉ុន្តែ [redacted] នៅរក្សាទុកមិនព្រមឱ្យ ។ នៅឆ្នាំ២០១៧ គាត់មានជម្ងឺគាត់ប្រកាសលក់ដីនឹងដាក់លេខទូរស័ព្ទនៅនឹងដីនឹងស្រាប់តែខាងមីក្រូហិរញ្ញវត្ថុក្រេឌីតគាត់មកសួរហេតុផលថាលេខទូរស័ព្ទនឹងឈ្មោះអ្នកណាគេឈ្មោះ [redacted] តែដីនឹងជាដីរបស់ [redacted] តាស នៅពេលនឹងហើយទើបបែកការថាដឹងថាអង្គហេតុរញ៉េរញ៉ៃយ៉ាងម៉េច ពេលលក់ហើយ [redacted] ទើបទៅសួរ [redacted] ថាតើ [redacted] បានលក់ដីឱ្យ [redacted] ទេ អត់ទេ អញ្ចឹងពេលទៅសួរនឹងគាត់នាំមេភូមិទៅផង កើតរឿង [redacted] ធ្វើលិខិតបញ្ជាក់ថាគាត់មិនបានធ្វើលិខិតលក់ដីនឹងឱ្យ [redacted] ម្តងណាទេ ហើយក៏មិនដែលផ្តិតមេដៃរមេភូមិបញ្ជាក់អញ្ចឹង ។ បន្ទាប់មកទៀតមានការដោះស្រាយទៅឈ្មោះ [redacted] បានព្រមព្រៀងនៅឆ្នាំ២០១៧ រកឃើញថានឹងប្រគល់លិខិតប្រគល់ដីទៅឱ្យឈ្មោះ [redacted] វិញនៅពេលណាដែលសងប្រាក់មីក្រូហិរញ្ញវត្ថុចប់ ពេលនោះហើយដែល [redacted] នឹងមិនបានយកប្រាក់ទៅបង់ឱ្យគេនោះទេ ដោយ [redacted] គាត់ខ្លាចបាត់បង់ដីរបស់គាត់ក៏យកប្រាក់ទៅបង់ជំនួសទៅទើបគេប្រគល់លិខិតផ្ទេរសិទ្ធិដីនឹងឱ្យ ដល់តែមើលឯកសារនឹងទៅ [redacted] គាត់អះអាងថាគាត់មិនបានផ្តិតមេដៃនោះទេ ហើយឈ្មោះ [redacted] ជាកូនបង្កើតរបស់ [redacted] ក៏ថាមិនបានផ្តិមេដៃធ្វើជាសាក្សីទេ អញ្ចឹងហើយបានជាកើតរឿងឱ្យធ្វើកោសលវិច័យមេដៃ កោសលវិច័យទី១ បានបញ្ជាក់ថាស្នាមមេដៃរបស់ឈ្មោះ [redacted] ដែលមាននៅលើលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ នោះគឺអត់ដូចទៅនឹងស្នាមម្រាមដៃទាំងដប់របស់ [redacted] ទេ ដែលធ្វើឱ្យទៅធ្វើកោសលវិច័យ ។ កោសលវិច័យទី២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ដោយសាររឿងព្រហ្មទណ្ឌជំនុំជម្រះហើយឯកោសលវិច័យនេះមិនទាន់បានទេទាក់ទងនឹងរឿងរដ្ឋប្បវេណីអញ្ចឹងកោសលវិច័យទី២ បានបញ្ជាក់ហើយថាស្នាមមេដៃនៅលើលិខិតផ្ទេរសិទ្ធិដីរបស់ឈ្មោះ [redacted] ជាអ្នកលក់នោះគឺអត់ដូចនៅស្នាមម្រាមដៃរបស់ឈ្មោះ [redacted] ដែលបានផ្តិតពេលដែលគាត់ធ្វើអត្តសញ្ញណបណ្ណ ។ សាក្សីឈ្មោះ [redacted] ជាមេភូមិគាត់ថាលិខិតនេះគាត់មិនបានយកទៅឱ្យអ្នកណាផ្តិមេដៃទេគឺឈ្មោះ [redacted] យកមកឱ្យគាត់ចុះហត្ថលេខាតែប៉ុណ្ណោះ ។ ក្នុងសវនាការពេលនេះឈ្មោះ [redacted] បានបញ្ជាក់យ៉ាងច្បាស់ហើយថា ឈ្មោះ [redacted] ជាសាក្សីនោះបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិដីនឹងចំពោះមុខគាត់ ហេតុអ្វីបានកោសលវិច័យបញ្ជាក់ថាស្នាមមេដៃកន្លែងសាក្សីឈ្មោះ [redacted] មិនមែនស្នាមម្រាមដៃរបស់ឈ្មោះ [redacted] ទេ ។ អង្គហេតុ សាក្សី ភស្តុតាង លិខិតកោសលវិច័យទាំងពីរច្បាស់ដែលបាន



[redacted]

អះអាងនេះបញ្ជាក់ថាជនជាប់ចោទពិតជាបានប្រព្រឹត្តលិខិតក្លែងដូចការចោទប្រកាន់ និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌទុកជាបានការដដែល ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ចំណុចទី១ សុំបញ្ជាក់ពីលិខិតផ្ទេរសិទ្ធិរបស់ [redacted] មកឱ្យ [redacted] ធ្វើឡើងនៅឆ្នាំ២០០៨ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានឈ្មោះ [redacted] ផ្ទេរសិទ្ធិមកឱ្យ [redacted] និងមានទាំងអាជ្ញាធរដឹងលឺ ចំពោះលោកមេធាវីដែលបានលើកឡើងថា [redacted] ធ្វើកោសលវិច័យស្នាមមេដៃទៅមិនពិតប្រាកដនេះគឺជាការលើកឡើងភស្តុតាងមកបញ្ជាក់ហើយទទួលស្គាល់ ប៉ុន្តែហេតុអ្វីបានជាអាជ្ញាធរគាត់ព្រមចុះហត្ថលេខានៅលើលិខិតនេះ ។ ចំណុចទី២ ទាក់ទងទៅនឹងលិខិតបញ្ជាក់អះអាងរបស់ [redacted] ថាគាត់មិនបានលក់ដីមកឱ្យ [redacted] ទេ តើលិខិតនេះមានទំនាក់ទំនងចំណុចណាដែលលោកលើកឡើងថាជាការពិត បើសិនជាលោកលើកឡើងថាអាជ្ញាធរដឹងលឺ ចុះហេតុអ្វីបានជាលិខិតអាជ្ញាធរដឹងលឺហើយលោកបដិសេធ ទាំងអស់នេះគឺមានលើកឡើងបញ្ជាក់ព្រមទាំងមានលិខិតបញ្ជាក់មួយចំនួនព្រមទាំងមានបង្កាន់ដៃដែលកូនក្តីខ្លួនកំពុងកាន់ សូមបញ្ជាក់ផងដែរចម្លើយរបស់ [redacted] ដែលឆ្លើយនៅដំណាក់កាលសាលាដំបូងនៅឆ្នាំ២០០៦ ប្រពន្ធខ្លួនបានស្លាប់ហើយក៏បានយកបង្កាន់ដៃបង់ប្រាក់លើដីដែលបានទិញនោះរក្សាទុកនៅ [redacted] នេះទៅយកបង្កាន់ដៃទាំងអស់នេះទាំងប្លង់ទៅដាក់ធនាគារដើម្បីយកប្រាក់មកឱ្យគាត់ដែលដូចលើកឡើងរបស់លោកមេធាវី ។ ចំណុចទី៣ កូនក្តីខ្លួនបានបញ្ជាក់ហើយថា ការទិញរបស់គាត់នឹងគឺទិញក្នុងឆ្នាំ១៩៩៧ ហើយធ្វើលិខិតផ្ទេរសិទ្ធិនេះនៅក្នុងឆ្នាំ២០០៨ ទេ ដែលមាន [redacted] ដែលជាម្ចាស់កម្មសិទ្ធិគាត់មានស្មារតីគ្រប់គ្រាន់ក្នុងការផ្ទេរសិទ្ធិ ប៉ុន្តែមកដល់ឆ្នាំ២០១៧ លោក [redacted] គាត់ថាការធ្វើលិខិតនេះគឺក្លែងក្លាយអញ្ចឹងហេតុអ្វីក្នុងពេលគាត់ដឹងថាគាត់ផ្តិតមេដៃនេះគាត់ប្តឹងទៅម៉េចក៏ទុកដល់ឆ្នាំ២០១៧ បានប្តឹង ។ ដោយសារគាត់ដឹងនឹងគឺគាត់ផ្តិតមេដៃនៅពេលដែលគាត់ប្រគល់សិទ្ធិទៅឱ្យ [redacted] យកប្លង់នេះទៅដាក់ធនាគារ ។ ស្នើសុំឱ្យក្រុមប្រឹក្សាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ព្រោះលិខិតដែលគាត់កាន់កាប់បច្ចុប្បន្ននេះគឺជាលិខិតត្រឹមត្រូវតាមច្បាប់ ដែលទទួលស្គាល់ពីអាជ្ញាធរ ។

-លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា៖ ចំណុចទី១ យោងទៅលើលិខិតផ្ទេរដីចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ទាក់ទងទៅនឹងកោសលវិច័យដែលលោកមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងមិនអាចយកជាការបានទេ ពីព្រោះជាលទ្ធផលនីតិវិធីកោសលវិច័យត្រូវយកសាមីខ្លួនមកផ្តិតមេដៃទាំង១០ ហើយការធ្វើឡើងគឺក្រសួងមហាផ្ទៃជាអ្នករៀបចំមិនអាចយកគំនូសស្នាមមេដៃបែបនឹងយកទៅផ្ទៀងផ្ទាត់ជាមួយអត្តសញ្ញាណប័ណ្ណនៅស្រុកបានទេ លុះត្រាយកសាមីខ្លួនទៅទើបអាចបញ្ជាក់បានច្បាស់ ។ មួយទៀតបើសិនជាឈ្មោះ [redacted] គាត់ពិតជាបានទិញដីពី [redacted] ពិតប្រាកដ ហេតុអ្វីមិនមានលិខិតទិញលក់ ។ម្យ៉ាងទៀតមើលទៅអង្គហេតុកូនក្តីខ្លួន [redacted] គាត់ជាជនរងគ្រោះសុទ្ធសាធ ដោយសារមានអង្គហេតុថាមានការទិញដីពី [redacted] ហើយគាត់មានសិទ្ធិផ្ទេរសិទ្ធិពី [redacted] ត្រឹមត្រូវហើយមានអាជ្ញាធរដឹងលឺទៀត រហូតដល់គាត់ទៅខ្ចីលុយនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្រាក់និងមក ។ បន្ទាប់មកទៀតឪពុកចុងរបស់គាត់ឈ្មោះ [redacted] គាត់ដឹងថាដីនឹងត្រូវបានកូនគាត់យកទៅបញ្ចាំធនាគារគាត់ទៅដកប្លង់គាត់ទៅដកប្លង់មកវិញ ហើយបច្ចុប្បន្ននេះថ្វីត្បិតតែកូនក្តីខ្លួនគាត់ថាគាត់មានលិខិតផ្ទេរសិទ្ធិថាជាកម្មសិទ្ធិដីនឹងពិតប្រាកដមែន ប៉ុន្តែដីនឹងត្រូវបានឪពុកចុងគាត់ផ្ទេរសិទ្ធិឱ្យគេនៅឆ្នាំ២០១៩ បាត់ទៅហើយ ។ អញ្ចឹងខ្លួនថាគ្មានអង្គហេតុណាមួយដែលបញ្ជាក់ថា កូនក្តីខ្លួនក្លែងបន្លំឯកសារសាធារណៈហេតុអ្វីមានអាជ្ញាធរចុះហត្ថលេខាមិនមែនគាត់ជាអ្នកដើរផ្តិតមេដៃសាក្សីទេ គឺត្រូវធ្វើឡើងនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច



[redacted]

-ក្រោយពីបានស្តាប់អំណានរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] បានឆ្លើយថា មូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍នេះ ដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ហើយការសម្រេចផ្តន្ទាទោសខ្លួននេះ មានភាពអយុត្តិធម៌ណាស់ ។ ដីទំនាស់នេះជាដីរបស់ខ្លួនប្រាកដមែន ដោយដីនេះខ្លួនបានទិញពីឈ្មោះ [redacted] នៅឆ្នាំ១៩៩៧ ដោយឈ្មោះនេះ បានប្រគល់បង្កាន់ដៃបង់ប្រាក់ និងបង្កាន់ដៃទទួលពាក្យកាន់កាប់ដីឲ្យខ្លួនចំនួន ៤សន្លឹក ។ ខ្លួនមិនមែនជាអ្នករៀបចំលិខិតទិញលក់ ឬឯកសារផ្ទេរសិទ្ធិអ្វីទេ គឺមេភូមិជាអ្នកសរសេរបំពេញឲ្យ ។ ចំពោះលិខិតមួយដែលបានអះអាងថា ខ្លួននឹងប្រគល់ដីទំនាស់ទៅឪពុកវិញនោះ នៅពេលដែលខ្លួនបង់ប្រាក់ឲ្យធនាគាររួចរាល់ ហើយមូលហេតុដែលខ្លួនសុខចិត្តប្រគល់ឲ្យទៅឪពុកនោះ ដោយសារខ្លួនមានចិត្តអាណិតគាត់ ។ សព្វថ្ងៃដីនេះឈ្មោះ [redacted] បានលួចលក់ដីទំនាស់នេះបាត់ហើយ ។

៣-គ្រប់ដំណាក់កាលនៃនីតិវិធីឈ្មោះ [redacted] បានឆ្លើយអះអាងថា ដីទំនាស់នេះជាកម្មសិទ្ធិរបស់ខ្លួនដែលបានទិញពីឈ្មោះ [redacted] ក្នុងឆ្នាំ១៩៩៧ ចំណែកឯឈ្មោះ [redacted] បានឆ្លើយអះអាងថា ជាកម្មសិទ្ធិរបស់ខ្លួនដែលបានទិញពីឈ្មោះ [redacted] នៅឆ្នាំ១៩៩៧ ដែរ ។ ប៉ុន្តែតាមការពិនិត្យភស្តុតាងឈ្មោះ [redacted] មិនមានឯកសារណាបញ្ជាក់ថាជាម្ចាស់កម្មសិទ្ធិដីឡើយ ។ រីឯឈ្មោះ [redacted] មានបង្កាន់ដៃទទួលប្រាក់ចំនួន ៣សន្លឹក និងបង្កាន់ដៃទទួលពាក្យចំនួន ០១សន្លឹក ដែលមានឈ្មោះ [redacted] ជាម្ចាស់ដីដើម និងលិខិតផ្ទេរសិទ្ធិដីពីឈ្មោះ [redacted] មកឈ្មោះ [redacted] ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានការដឹងឮពីអាជ្ញាធរភូមិ ឃុំ ។ ចំពោះបង្កាន់ដៃទាំង៤សន្លឹកនេះឈ្មោះ [redacted] បានអះអាងថាខ្លួនបានផ្ញើរទៅឈ្មោះ [redacted] ទុកដាក់ ហើយឈ្មោះនេះមិនព្រមប្រគល់ឲ្យខ្លួនវិញទេ តែការអះអាងនេះមិនមានភស្តុតាងមកបញ្ជាក់ឡើយ ។

៤-ពិនិត្យភស្តុតាងមានក្នុងសំណុំរឿង គឺគ្មានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទបានប្រើប្រាស់លិខិតផ្ទេរសិទ្ធិ ដោយបានដឹងថាលិខិតនេះ ធ្វើឡើងមិនត្រឹមត្រូវដូចជាមានការបន្លំស្នាមមេដៃរបស់ភាគីនោះទេ



[redacted]

ព្រោះថាតាមចម្លើយរបស់ជនជាប់ចោទថា ខ្លួនបានទទួលបង្កាន់ដៃបង់ប្រាក់ចំនួន ០៣សន្លឹក និងបង្កាន់ដៃទទួលពាក្យចំនួន ១សន្លឹក ធ្វើនៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៨៩ ដែលមានឈ្មោះ [redacted] ជាម្ចាស់ដីបានប្រគល់មកឱ្យខ្លួនក្រោយពេលទិញដីនោះនៅឆ្នាំ ១៩៩៧ ។ ចំពោះលិខិតផ្ទេរសិទ្ធិដីធ្វើនៅឆ្នាំ២០០៨ ហើយបានប្រើប្រាស់រហូតមក ។ ដូច្នេះតាមចម្លើយរបស់ជនជាប់ចោទ និងឯកសារភស្តុតាង គឺបញ្ជាក់បានថា ជនជាប់ចោទពុំបានក្លែងបន្លំឯកសារសាធារណៈ ដែលមានហត្ថលេខាទទួលស្គាល់ដោយអាជ្ញាធរភូមិ និងឃុំ មានស្នាមមេដៃភាគីអ្នកលក់ឈ្មោះ [redacted] និងអ្នកទិញឈ្មោះ [redacted] និងមានចុះលេខ និងបោះត្រាត្រឹមត្រូវនោះទេ ។

៥-តាមការឆ្លើយបំភ្លឺរបស់មេភូមិឈ្មោះ [redacted] ដែលបានបញ្ជាក់ថា លិខិតផ្ទេរសិទ្ធិនេះ ខ្លួនជាអ្នករៀបចំហើយឈ្មោះ [redacted] បានយកឱ្យម្ចាស់ដី និងសាក្សីផ្តិតមេដៃ មុនពេលយកមកឱ្យខ្លួនបញ្ជាក់ ។ ការឆ្លើយបំភ្លឺនេះមិនអាចឱ្យតុលាការជឿបានឡើយ ព្រោះក្នុងនាមជាអាជ្ញាធរដែនដីដែលច្បាប់ប្រគល់សិទ្ធិឱ្យ មិនចេះតែចុះហត្ថលេខាហើយបដិសេធជាក្រោយនោះទេ ហើយក្នុងលិខិតផ្ទេសិទ្ធិដីនេះការបញ្ជាក់របស់មេភូមិបេងឈ្មោះ [redacted] ដាក់ថាឈ្មោះ [redacted] បានព្រមព្រៀងផ្ទេរសិទ្ធិដីជូន ឈ្មោះ [redacted] ពិតប្រាកដមែន និងមេឃុំអន្លង់វិលឈ្មោះ [redacted] បានបញ្ជាក់ថាហត្ថលេខានេះជារបស់ឈ្មោះ [redacted] ប្រាកដមែន ។ ដូច្នេះច្បាស់ណាស់ការបញ្ជាក់លើលិខិតលក់ទិញ ត្រូវមានភាគី និងសាក្សីផ្តិតស្រាមដៃចំពោះមុខខ្លួនជាមុន ទើបខ្លួនចុះហត្ថលេខាបញ្ជាក់តាមក្រោយ ។

៦-សាក្សីបំភ្លឺឈ្មោះ [redacted] ដែលបានឆ្លើយថាខ្លួនមិនបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិដីចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០០៨ ទេ ការឆ្លើយនេះមិនមានមូលដ្ឋានឱ្យតុលាការជឿបានឡើយ ព្រោះលិខិតនេះធ្វើឡើងតាំងពីឆ្នាំ ២០០៨ រហូតដល់ពេលចូលឆ្លើយនេះគឺមានរយៈពេលជិត ១២ឆ្នាំហើយ ដូច្នេះសាក្សីនេះអាចភ្លេច ឬភាន់ច្រលំបាន ។ ម្យ៉ាងគ្មានលិខិតពេទ្យណាដែលបញ្ជាក់ថា សាក្សីនេះមានស្មារតីល្អ និងមិនមានជម្ងឺភ្លេចភ្លាំងឡើយ ។

៧-លិខិតធានាអះអាងរបស់ម្ចាស់ដីឈ្មោះ [redacted] (ជាឯកសារថតចម្លង) ការបញ្ជាក់នេះមិនមានអានុភាពគតិយុត្តិ យកជាមូលដ្ឋានឱ្យតុលាការជឿឡើយ ព្រោះថាលិខិតនេះធ្វើឡើងមិនបានចុះកាលបរិច្ឆេទថ្ងៃខែឆ្នាំទេ ហើយការបញ្ជាក់របស់មេភូមិ និងមេឃុំ ធ្វើនៅកាលបរិច្ឆេទខុសគ្នា នៅមេភូមិចុះថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០១៧ មេឃុំចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ដោយឈ្មោះ [redacted] បានទទួលមរណៈភាពនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ គឺធ្វើមុនពេលស្លាប់តែ១ខែជាងបន្តិចប៉ុណ្ណោះ ។ ត្រង់ចំណុចនេះបញ្ជាក់ថាសាក្សីនេះមានស្មារតីមិនគ្រប់គ្រាន់ ក្នុងការឆ្លើយបញ្ជាក់ឡើយ ព្រោះកំពុងមានជម្ងឺធ្ងន់ធ្ងរ ឬ ជាការឆ្លើយអះអាងពិតប្រាកដដែរឬទេ ។ ដូច្នេះការធានាអះអាងនេះមិនមានតម្លៃជាភស្តុតាង ដែលអាចឱ្យសភាព្រហ្មទណ្ឌលើកយកមកពិចារណាបានទេ ។

៨-ចំពោះលទ្ធផលនៃកោសលវិច័យលេខ ០៦៥/២០ចល.របក ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០២០ របស់នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ ត្រង់សេចក្តីសន្និដ្ឋានចំណុច ៣.៣ ដែលបានបញ្ជាក់ថា ស្នាមមេដៃសរសេរឈ្មោះ [redacted] និងក្នុងលិខិតផ្ទេរសិទ្ធិដី ចុះថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០០៨ (ឯកសារទី១) ប្រៀបធៀបជាមួយស្នាមមេដៃរបស់ឈ្មោះ [redacted] ដែលបានផ្តិតលើឯកសារកំណត់ហេតុស្តីពីការផ្តល់ស្នាមម្រាមដៃចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០២០ របស់ចៅក្រម គឺមិនដូចគ្នា ។ នេះគ្រាន់តែបញ្ជាក់ថាស្នាមមេដៃសាក្សីមិនដូច



[redacted]

គ្នាប៉ុណ្ណោះ មិនបានបញ្ជាក់ថាលិខិតនេះទាំងស្រុងក្លែងក្លាយទេ ។ ដូច្នេះនេះជាទម្រង់លិខិតពិតប្រាកដ ដែលមានភាគីអ្នកទិញ និងអ្នកលក់បានផ្តិតមេដៃ និងអាជ្ញាធរមូលដ្ឋានចុះហត្ថលេខាដឹងឮ ហើយគ្មានអាជ្ញាធរមានសមត្ថកិច្ចណាមួយ បានបោះត្រាទុកជាមោឃៈភាពលើលិខិតនេះទេ មានន័យថាលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០០៨ នៅមានសុពលភាពគតិយុត្តិនៅឡើយ ។

៩-តំណាងមហាអយ្យការបានសន្និដ្ឋាន សូមតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។ សេចក្តីសន្និដ្ឋាននេះ គ្មានទឡ្ហីករណ៍សមស្របដែលអាចឲ្យសភាព្រហ្មទណ្ឌ លើកយកមកពិចារណា និងសម្រេចបានឡើយ ។

១០-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា ស្នើសុំតម្កល់សាលក្រមទុកជាបានការដដែល ។ សេចក្តីសន្និដ្ឋាននេះគ្មានសំអាងហេតុ និងសំអាងច្បាប់សមស្របអាចឲ្យសភាព្រហ្មទណ្ឌ ទទួលយកមកពិចារណា និងសម្រេចបានទេ ។

១១-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ស្នើសុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិទាំងពីររូប មានអំណះអំណាង និងភស្តុតាងមកបញ្ជាក់គ្រប់គ្រាន់ អាចឲ្យសភាព្រហ្មទណ្ឌមានមូលដ្ឋានលើកយកមកពិចារណា និងសម្រេចបាន ។

១២-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ សាក្សី និងភស្តុតាងជាឯកសារ ដែលមានក្នុងសំណុំរឿង គឺបញ្ជាក់បានថា ជនជាប់ចោទគ្មានចេតនាទុច្ចរិតក្នុងការក្លែងបន្លំឯកសារសាធារណៈឡើយ ។ ការប្តឹងចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌនេះ និងការចោទប្រកាន់បញ្ជូនមកជំនុំជម្រះ គ្មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការកំណត់ពិរុទ្ធភាពលើជនជាប់ចោទបានទេ ហើយម្យ៉ាងសំណុំរឿងទាមទារតាមផ្លែករដ្ឋប្បវេណីមិនទាន់ស្ពាពរ កំពុងតែដំណើរការនៅសាលាឧទ្ធរណ៍នៅឡើយ និងមិនទាន់បញ្ជាក់ថាភាគីណាមួយមានសិទ្ធិលើដីវិវាទទេ ។ ដោយយោងតាមមាត្រា ៣៥១ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។ ដូច្នេះគប្បីសភាព្រហ្មទណ្ឌពិចារណាឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ។

១៣-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៧ឆ្នាំ ពីបទ ៖ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

១៤-សាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ “ង” ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ដែលសម្រេចសេចក្តីមកនេះ ពុំមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ឡើយ គប្បីបដិសេធចោលជាអសារបង់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។



[redacted]

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ង" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ចោលជាអសារបង់ ។

៣-ឲ្យជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៩ឆ្នាំ (មានសាវតាជាតិដូចខាងលើ) រួចខ្លួនពីការចោទប្រកាន់ពីបទ ៖ ក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជា សាធារណៈ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ ។

រក្សាសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សាលាឧទ្ធរណ៍បាត់ដំបង, ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



[redacted]